ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សាររំលែកមរណទុក្ខ

**ផ្ញើជូន**
**ឯកឧត្តម ខួន សុជាតិ អ្នកតំណាងរាស្ត្រ និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកស្តាយរញ្ជួយចិត្តក្រៃលែង ដោយបានទទួលដំណឹងថា **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ខួន ញឹល អនុប្រធានទី១ នៃរដ្ឋសភា** បានទទួលមរណភាពនៅថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១០:៣៦ នាទីព្រឹក ក្នុងជន្មាយុ ៧៩ឆ្នាំ។

មរណភាពរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ខួន ញឹល** គឺជាការបាត់បង់នូវឪពុក និងជីតាប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជាការបាត់បង់ឥស្សរជនមួយរូប ដែលពោរពេញដោយឆន្ទៈមនសិការការងារក្នុងការបម្រើ **ជាតិ សាសនា ព្រះមហាក្សត្រ** ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យជាអនេកប្បការជាមួយ **ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ**។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ខួន ញឹល** បានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃ សុក្រ ១ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ហ៊ុំ-សុខា

ផ្លូវវិត្តអង្គតាម៉ុញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh